## តើជំងឺអុតស្វាវីករាលដាលដល់កម្រិតណាហើយ នាពេលឥឡូវនេះ?

ចាប់តាំងពីថ្ងៃទី 13 ខែឧសភា ឆ្នាំ 2022 មក មានការរាយការណ៍ថាមានការផ្ទុះឡើងនៃជំងឺអុតស្វានៅបណ្តាប្រទេសជាច្រើន ដែលកន្លងមកមិនធ្លាប់មានករណីឆ្លងនៃជំងឺនេះទេ។ ករណីឆ្លងជាច្រើននាពេលថ្មីៗនេះ ត្រូវបានរាយការថាមិនមានការជាប់ពាក់ព័ន្ធជាមួយនឹងសត្វដែលមានជំងឺ ឬការធ្វើដំណើរទៅកាន់តំបន់ដែលធ្លាប់មានផ្ទុះជំងឺនេះ នោះទេ។ តំបន់ជាច្រើននៅក្នុងសហរដ្ឋអាមេរិកក៏បានរកឃើញថាមានករណីឆ្លងជាច្រើន ហើយនៅក្នុងនោះក៏រួមមានទាំងរដ្ឋកាលីហ្វ័រញ៉ាផងដែរ។

**ប្រសិនបើអ្នកគិតថាអ្នកអាចនឹងមានជំងឺអុតស្វា សូមទាក់ទងទៅកាន់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក។**

**ប្រសិនបើអ្នកមិនមានអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព ឬធានារ៉ាប់រងសុខភាពទេ សូមហៅទៅកាន់លេខ 2-1-1 ឬក៏ទៅកាន់គ្លីនិកសុខភាពសាធារណៈដែលនៅក្បែរអ្នក។**

សូមស្កេននៅទីនេះ ដើម្បីស្វែងរកគ្លីនិកផ្នែកសុខភាពផ្លូវភេទ

**សម្រាប់ព័ត៌មានបន្ថែមអំពីជំងឺអុតស្វា សូមចូលទៅកាន់គេហទំព័រ៖**

ph.lacounty.gov/media/Monkeypox/

(Cambodian) Revised 6/30/2022

# អ្វីដែលអ្នកគួរតែស្វែងយល់អំពី ជំងឺអុតស្វា នៅក្នុងខោនធី LA



County of Los Angeles Public Health

## ចំណុចសំខាន់ៗ៖

- ជំងឺអុតស្វាមិនងាយនឹងឆ្លងពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ទេ។
- នាពេលបច្ចុប្បន្ននេះ នៅមិនទាន់មានវិធីជាក់លាក់ដែលទទួលបានការអនុម័ត សម្រាប់ព្យាបាលជំងឺអុតស្វានៅឡើយទេ ប៉ុន្តែអាចនឹងមានផ្តល់ជូនថ្នាំពេទ្យមួយចំនួនដើម្បីសម្រាលរោគសញ្ញានានា។
- ដើម្បីជួយទប់ស្កាត់ជំងឺអុតស្វា សូមជៀសវាងការប៉ះពាល់ជាមួយនឹងសត្វ ឬមនុស្ស ដែលអាចនឹងមានមេរោគ ហើយជៀសវាងការប៉ះពាល់ជាមួយនឹងសម្ភារដែលបានប៉ះពាល់ទៅនឹងសត្វ ឬមនុស្សដែលឈឺ និងអនុវត្តការថែរក្សាអនាម័យដៃឲ្យបានល្អ បន្ទាប់ពីបានប៉ះពាល់ជាមួយនឹងសត្វ ឬមនុស្សដែលឆ្លងជំងឺ។

## តើអ្វីទៅជាជំងឺអុតស្វា?

ជំងឺអុតស្វាគឺជាប្រភេទជំងឺកម្រមួយដែលបង្កឡើងដោយការឆ្លងមេរោគអុតស្វា ហើយដែលអាចបណ្តាលឲ្យអ្នកធ្លាក់ខ្លួនឈឺ។ តាមធម្មតា គេរកឃើញជំងឺនេះនៅតំបន់ផ្សេងក្រៅពីសហរដ្ឋអាមេរិក តែទោះជាយ៉ាងណាក៏ដោយ នាពេលថ្មីៗនេះ មានករណីជាច្រើនត្រូវបានរាយការណ៍ថាមាននៅក្នុងរដ្ឋកាលីហ្វ័រញ៉ា និងក្នុងខោនធី Los Angeles។



## តើជំងឺអុតស្វារីករាលដាលតាមរបៀបណា?

ជំងឺអុតស្វារីករាលដាលនៅពេលដែលមនុស្សម្នាក់ប៉ះពាល់ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងមនុស្សម្នាក់ដែលមានមេរោគអុតស្វា ឬក៏នៅពេលមនុស្សម្នាក់បានប៉ះពាល់ទៅនឹងសម្ភារ (ដូចជា កម្រាលពូក ឬស្រោមខ្នើយ ឬកន្សែងជូតខ្លួន) ដែលបានប្រឡាក់ទៅនឹងមេរោគនោះ។ មេរោគអុតស្វាក៏អាចរីករាលដាលពីសត្វមកកាន់មនុស្សផងដែរ។

## មេរោគអុតស្វាអាចរីករាលដាលតាមរយៈ៖

- ការប៉ះពាល់ទៅនឹងដំបៅអុតស្វានៅលើស្បែករបស់មនុស្សម្នាក់
- ការប៉ះពាល់ទៅនឹងសម្ភារ ឬសាច់ក្រណាត់នានា (សម្លៀកបំពាក់ កម្រាលពូក ឬស្រោមខ្នើយ កន្សែងជូតខ្លួន) ដែលបានប្រឡាក់ទៅនឹងមេរោគ និងផ្ទៃនានាដែលបានប៉ះពាល់ដោយបុគ្គលដែលមានជំងឺអុតស្វា
- ការប៉ះពាល់ទៅនឹងតំណក់ទឹកតូចៗតាមផ្លូវដង្ហើម ឬសារធាតុរាវផ្សេងៗដែលចេញពីភ្នែក ច្រមុះ និងមាត់របស់បុគ្គលដែលមានជំងឺអុតស្វា

## ដើម្បីទប់ស្កាត់ការរីករាលដាលនៃមេរោគអុតស្វា បុគ្គលទាំងឡាយគួរតែជៀសវាង៖

- ការរួមភេទតាមមាត់ តាមទ្វារធំ និងតាមទ្វារមាស ឬការប៉ះពាល់ប្រដាប់ភេទ ឬទ្វារធំរបស់នរណាម្នាក់ដែលមានជំងឺអុតស្វា
- ការឱប ការម៉ាស្សា ការថើប ឬការនិយាយនៅក្បែរគ្នាជាមួយនឹងបុគ្គលដែលមានជំងឺអុតស្វា
- ការប៉ះពាល់ទៅនឹងសាច់ក្រណាត់ ឬផ្ទៃដែលប្រើប្រាស់រួមគ្នា និងរបស់របរនានា (ឧ. ប្រដាប់ប្រដាលេងពេលរួមភេទ [sex toys]) ដែលបានប្រើប្រាស់រួចដោយបុគ្គលដែលមានជំងឺអុតស្វា

## តើសញ្ញានៃជំងឺអុតស្វាមានអ្វីខ្លះ?

សញ្ញាដំបូងៗអាចមានដូចជា គ្រុនក្តៅ ភាពល្ហិតល្ហៃ (ពិបាកក្នុងខ្លួន) ឈឺក្បាល ហើមកូនកណ្តុរ និងពេលខ្លះក្អក ឬឈឺបំពង់កផងដែរ។ រោគសញ្ញាផ្សេងទៀតមានដូចជា ឈឺសាច់ដុំ ចុកខ្នង គ្រុនរងា និងអស់កម្លាំង ហើយបន្ទាប់មកមានឡើងកន្ទួលរមាស់ ដែលជាធម្មតាចាប់ផ្តើមចេញនៅលើមុខ ហើយរាលដាលដល់ផ្នែកផ្សេងទៀតនៅលើដងខ្លួន។ ជំងឺនេះអាចនឹងបាត់ទៅវិញក្នុងរយៈពេលពី ពីរទៅបួន សប្តាហ៍។ ហើយមនុស្សមួយចំនួនគ្រាន់តែមានឡើងកន្ទួលរមាស់ ព្រមទាំងពេលខ្លះមានហើមកូនកណ្តុរ និងពេលខ្លះមិនមានដែលកន្ទួលរមាស់នេះអាចនឹងចេញនៅលើប្រដាប់ភេទផងដែរ។



**គ្រុនក្តៅ & ឈឺក្បាល**



**ឈឺសាច់ដុំ**



**កន្ទួលរមាស់ ឡើងពក ឬពងបែក**



**ហើមកូនកណ្តុរ**



## ការព្យាបាល និងការទទួលចាក់ថ្នាំបង្ការ៖

នាពេលឥឡូវនេះ នៅមិនទាន់មានវិធីជាក់លាក់ដែលទទួលបានការអនុម័តសម្រាប់ព្យាបាលជំងឺអុតស្វានោះទេ។ ទោះជាយ៉ាងណាក៏ដោយ អាចនឹងមានការផ្តល់ថ្នាំពេទ្យដូចជា ថ្នាំប្រឆាំងមេរោគ (antiviral) ដើម្បីសម្រាលរោគសញ្ញានានានៃជំងឺ។ ក្នុងករណីមួយចំនួន អាចមានការផ្តល់ថ្នាំបង្ការសម្រាប់ទប់ស្កាត់ការឆ្លងជំងឺអុតស្វាបន្ទាប់ពីមានការប៉ះពាល់ទៅនឹងមេរោគនេះ។ សូមពិគ្រោះជាមួយនឹងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកអំពីជម្រើសនៃការព្យាបាលដែលមានផ្តល់ជូនទាំងឡាយ។